# ប្រកាសព័ត៌មាន

## ជួយជនរងគ្រោះដោយសារការជួញដូរមនុស្សឱ្យធ្វើសមាហរណកម្មវិញ នៅក្នុងប្រទេសមហាអនុតំបន់មេគង្គ

**ក្រុងបាងកក ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧- ថ្ងៃនេះ ឧបករណ៍ថ្មីមួយសម្រាប់គាំទ្រដល់ការធ្វើសមាហរណកម្មជនរងគ្រោះដោយសារការជួញដូរមនុស្សត្រូវបានចេញផ្សាយដោយវិទ្យាស្ថាន** NEXUS Institute សកម្មភាពអង្គការសហប្រជាជាតិ ដើម្បីសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស (UN-ACT) និងអង្គការទស្សនៈពិភពលោក (World Vision)។ សៀវភៅណែនាំដែលមានឈ្មោះថា *គាំទ្រការធ្វើសមាហរណកម្មជនរងគ្រោះដោយសារការជួញដូរមនុស្ស៖ សៀវភៅណែនាំសម្រាប់មហាអនុតំបន់មេគង្គ* រៀបចំឡើយ សម្រាប់អ្នកអនុវត្តការងារផ្ទាល់នៃស្ថាប័នរដ្ឋាភិបាលនិងមិនមែនរដ្ឋាភិបាល ដើម្បីដោះស្រាយនៅចំណុចខ្វះខាតនៅក្នុងការជួយជនរងគ្រោះនិងការធ្វើសមាហរណកម្មជនរងគ្រោះ នៅក្នុងមហាអនុតំបន់មេគង្គ (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម)។

សៀវភៅណែនាំនេះគូសបញ្ជាក់អំពីគំរូល្អៗនៃការធ្វើសមាហរណកម្មជនរងគ្រោះ និងភាពប្រឈមនានាដែលជនរងគ្រោះភាគច្រើនជួបប្រទះ នៅពេលពួកគេព្យាយាមរត់គេចពីការកេងប្រវ័ញ្ច។ សៀវភៅនេះក៏ផ្តល់ការណែនាំជាក់ស្តែងសម្រាប់អ្នកអនុវត្តការងារ តាមរយៈបញ្ជីផ្ទៀងផ្ទាត់និងអនុសាសន៍ ស្តីពីរបៀបធ្វើឱ្យប្រសើរឡើងដល់កម្មវិធីនិងគោលនយោបាយនៃការធ្វើសមាហរណកម្ម។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើករបកគំហើញនៃការស្រាវជ្រាវថ្នាក់តំបន់មួយដែលមានឈ្មោះថា *បន្ទាប់ពីត្រូវបានគេជួញដូរ៖ បទពិសោធន៍និងភាពប្រឈមនៅក្នុងការធ្វើសមាហរណកម្មជនរងគ្រោះនៅក្នុងមហាអនុតំបន់មេគង្គ* ដែលបានចេញផ្សាយនៅក្នុងឆ្នាំ២០១៣ ដោយវិទ្យាស្ថាននិកសឹស និង UN-ACT ដែលពីមុនមានឈ្មោះថា "UNIAP" ។ ការសិក្សានេះធ្វើឡើយដោយការសម្ភាសស៊ីជម្រៅជាមួយនឹងជនរគ្រោះរាប់រយនាក់នៅក្នុងមហាអនុតំបន់មេគង្គ ហើយបានរកឃើញការអនុវត្តនិងមេរៀនល្អៗដែលទទួលបានពីជនរងគ្រោះនៅក្នុងមហាអនុតំបន់។

លោកស្រី Rebecca Surtees អ្នកស្រាវជ្រាវជាន់ខ្ពស់របស់វិទ្យាស្ថាន និកសឹស និងជាអ្នកនិពន្ធ នៃរបាយការណ៍ការស្រាវជ្រាវនិងសៀវភៅណែនាំនេះមានប្រសាសន៍ថា “*ជនរងគ្រោះជាង២៥០នាក់នៅក្នុងប្រទេសទាំង៦ បានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួននិងការឆ្លុះបញ្ចាំងរបស់ពួកគេអំពីជីវិត ក្រោយពីត្រូវបានគេជួញដូរ។ សៀវភៅនេះរៀបចំឡើងដោយផ្អែកលើបទពិសោធន៍ទាក់ទងនឹងការធ្វើសមាហរណកម្មនិងអនុសាសន៍របស់ពួកគេអំពីរបៀបធ្វើឱ្យប្រសើរឡើងដល់ការធ្វើសមាហរណកម្មជនរងគ្រោះ*”។

សៀវភៅណែនាំនេះត្រូវបានបកប្រែជា៦ភាសា។ សៀវភៅនេះនឹងត្រូវបានចែកចាយដល់អង្គការនិងស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់ សម្រាប់គាំទ្រដល់ការងារជួយជនរងគ្រោះដោយសារការជួញដូរមនុស្ស។ លោកស្រី Amy Collins អ្នកសម្របសម្រួលកម្មវិធីថ្នាក់តំបន់របស់គម្រោង បញ្ឈប់អំពើហឹង្សាលើកុមារ អង្គការទស្សនៈពិភពលោក បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការអនុវត្តសៀវភៅនេះ ដើម្បីធ្វើឱ្យប្រសើរឡើងដល់កិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្មជនរងគ្រោះ៖ “*អង្គការទស្សនៈពិភពលោកដែលមានហេត្ថារចនាសម្ព័ន្ធនៅក្នុងប្រទេសទាំងនេះសម្រាប់ដោះស្រាយបញ្ហាជួញដូរមនុស្សតាមរយៈគោលនយោបាយ ការកៀរគរមតិ និងការអនុវត្តផ្ទាល់ ត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រដល់ការអនុវត្តសៀវភៅណែនាំនេះ*”។

ការសិក្សានិងសៀវភៅណែនាំនេះគឺជាឧទាហរណ៍ដ៏ប្រសើរនៃកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ប្រកបដោយប្រសិទ្ធិភាព តាមរយៈកិច្ចសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងនឹងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ហៅកាត់ថា ខមមីត (COMMIT)។ ខមមីតគឺជាយន្តការមួយសម្រាប់កិច្ចសហប្រតិបត្តិការទ្វេនិងពហុភាគីប្រឆាំងនឹងការជួញដូរមនុស្ស ដោយផ្អែកលើអនុស្សរណៈនៃការយោគយល់គ្នានៅក្នុងចំណោមប្រទេសទាំង៦ ក្នុងមហាអនុតំបន់មេគង្គ។ UN-ACT ដែលពីមុនមានឈ្មោះថា UNIAP ដើរតួជាលេខាធិការដ្ឋានឱ្យ ខមមីត ចាប់តាំងពីខមមីតបានបង្កើតឡើង។

លោកស្រី Kaori Kawarabayashi នាយក UN-ACT ថ្នាក់តំបន់ បញ្ជាក់ពីតួនាទីសំខាន់របស់ ខមមីត នៅក្នុងការធ្វើឱ្យប្រសើរឡើងដល់ការធ្វើសមាហរណកម្មជនរងគ្រោះ៖ *"ការសិក្សាស្រាវជ្រាវត្រូវបានធ្វើនៅក្នុងបរិបទនៃគំនិតផ្តួចផ្តើមថ្នាក់តំបន់អំពីការធ្វើសមាហរណកម្មជនរងគ្រោះ ដែលរដ្ឋាភិបាលទាំង៦ បានយល់ព្រម។ ដោយសារខមមីត យើងអាចបង្កើតឱ្យមានការសិក្សាស្រាវជ្រាវនិងសៀវភៅណែនាំនេះឡើង ហើយឥឡូវនេះ យើងត្រូវធ្វើការងារដើម្បីធ្វើឱ្យប្រសើរដល់គោលនយោបាយនិងកម្មវិធីសមាហរណកម្មនៅទូទាំងមហាអនុតំបន់មេគង្គ ឱ្យស្របតាមបទដ្ឋានអន្តរជាតិ"*។

**ចប់**

***

ដើម្បីមើលនិងទាញយកសៀវភៅនេះសូមចុច here.
ដើម្បីមើលនិងទាញរបាយការណ៍នៃការស្រាវជ្រាវសូមចុច here.

**<u>ពត៌មានបន្ថែមសូមទាក់ទង:</u>**

វិទ្យាស្ថាននិកសឺស: លោកស្រី Rebecca Surtees, អ្នកស្រាវជ្រាវជាន់ខ្ពស់, rsurtees@nexusinstitute.net

UN-ACT: លោក Sebastian Boll, អ្នកឯកទេសផ្នែកស្រាវជ្រាវថ្នាក់តំបន់ sebastian.boll@undp.org

World Vision: លោក្រសី Amy Collins, អ្នកសម្របសម្រួលកម្មវិធីថ្នាក់តំបន់, amy_collins@wvi.org